**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jan-2014, 15:28
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស និង ខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីអំពីវិសាលភាពនៃសំណុំរឿង ០០២/០២**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

គង់ ផល្លៈ

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន ស៊ុវ៉ន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

យ៉េត ចរិយា

គង់ ពិសី

យ៉ុង ផានិត

សំ សុគង់

វ៉េន ពៅ

ទី ស្រីនណា

Emmanuel ALTIT
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Jeanne SULZER
Philippine SUTZ
Beini YE

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGES

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

Pascal AUBOIN

## I. សេចក្ដីផ្ដើម

1. បន្ថែមទៅនឹងវិសាលភាពស្នើឡើងដោយព្រះរាជអាជ្ញា[1] ដែលខ្លួនបានគាំទ្រនោះ ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យមានការពង្រីកវិសាលភាពនៃបទចោទអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការប្រព្រឹត្តចំពោះពុទ្ធសាសនិក រហូតទៅដល់វិសាលភាពទូទាំងប្រទេស និងមិនកម្រិតត្រឹមទីកន្លែងឧក្រិដ្ឋកម្មមួយចំនួននោះឡើយ។ លើសពីនេះទៀត ពួកគាត់ស្នើសុំឱ្យដាក់បញ្ចូលទីកន្លែងចំនួនបី និងបទចោទមួយបន្ថែមទៀតទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២៖ ការដ្ឋានទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខភូមិភាគឧត្តរ មន្ទីរសន្តិសុខកោះខ្យង និងការជម្លៀសដោយបង្ខំដំណាក់កាលទី៣ ដោយរួមទាំងការបោសសំអាតដែលពាក់ព័ន្ធនៅភូមិភាគបូព៌ា។

2. នៅក្នុងការគាំទ្រសំណើរបស់ពួកគាត់ស្ដីពីវិសាលភាពនៃសំណុំរឿង ០០២/០២ ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យមានការធានាថា ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងបទពិសោធន៍របស់ពួកគាត់ជាជនរងគ្រោះ ត្រូវបានតំណាងឱ្យបានយ៉ាងសមស្របនៅក្នុងការចោទប្រកាន់លើអង្គហេតុ និងការកំណត់បទល្មើសតាមច្បាប់នៃអង្គហេតុដែលត្រូវយកវិនិច្ឆ័យនៅក្នុងសំណុំរឿង ០០២/០២។ ពួកគាតបានបង្កើត និងគាំទ្រសំណើ របស់ពួកគាត់ ដោយផ្អែកជាចម្បងទៅលើចរិតលក្ខណៈ ទំហំ និងវិសាលភាពភូមិសាស្ត្រនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ និងកម្រិតដែលទីកន្លែង ឬឧក្រិដ្ឋកម្មជាក់លាក់ទាក់ទិននឹងប្រធានបទជាមូលដ្ឋាននៃរឿងក្ដី។

## II. ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ ការិយាល័យសហព្រះរាជអាជ្ញា "កសព" បានស្នើដាក់ទីតាំងឧក្រិដ្ឋកម្ម និងអង្គហេតុដែលបានចោទប្រកាន់ ដើម្បីបញ្ចូលទៅក្នុងសំណុំរឿង ០០២/០២[2]។

4. នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការដំបូងលើសំណុំរឿង ០០២/០២ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ពួកគាត់បានយល់ស្របជាគោលការណ៍ទៅនឹងវិសាលភាព

[1] ឯកសារ **E301/2** សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ពន្ធ ក ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៣ (បន្ទាប់ពីនេះហៅថា "ឯកសារ E301/2")។

[2] *ដូចខាងលើ*

នៃការជំនុំជម្រះសំណុំរឿង ០០២/០២ ដែលបានស្នើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា[3] ប៉ុន្តែមិនមែនទៅលើការដក (ឬ "ការទម្លាក់") បទចោទដែលនៅសេសសល់ ឬការចោទប្រកាន់ផ្នែកអង្គហេតុដែលមានកំណត់នៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២ ចេញពីកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ឡើយ[4]។

5. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញផែនការការងារមួយ និងបានស្នើសុំឲ្យភាគីទាំងអស់ដាក់សារណាជាលាយលក្ខណ៍អក្សរ ដែលពួកគេមានបំណងលើកឡើងទៅលើវិសាលភាពនៃសំណុំរឿង ០០២/០២ នៅត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤[5]។

## III. ច្បាប់ជាធរមាន

6. អង្គជំនុំជម្រះតុលាការកំពូល ("អជតក") បានកំណត់លក្ខខណ្ឌអប្បបរមាមួយ ដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវតែបំពេញនៅក្នុងការសម្រេចអំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ដោយតម្រូវថា វិសាលភាពនៃសំណុំរឿងនេះត្រូវមាន "ភាពជាតំណាងសមស្រប"[6] ហើយថា វិសាលភាពនេះរួមបញ្ចូល "បទចោទទាក់ទិននឹងមន្ទីរ ស-២១ ការដ្ឋានធ្វើការ សហករណ៍ និងអំពើប្រល័យពូជសាសន៍"[7]។

7. នៅក្នុងការថ្លឹងថ្លែងរវាងផលប្រយោជន៍នៃសវនាការប្រកបដោយយុត្តិធម៌ និងឲ្យបានឆាប់រហ័ស ទល់នឹងតម្រូវការឲ្យមានសវនាមួយដែលធ្វើជាតំណាងសមស្របនៃដីកាដំណោះស្រាយនោះអង្គជំនុំជម្រះតុលាការកំពូលបានលើកយកវិធាន ៧៣ស្ទួន(ឃ) នៃវិធានស្តីពីនីតិវិធី និងការដាក់ភ័ស្តុតាង

---

[3] ឯកសារ **E1/238.2** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ERN 00966140 **E1/238.2** ត្រង់បន្ទាត់ 23-25 (ភាសាអង់គ្លេស)។

[4] ដូចយោងខាងលើ ERN 00966141 ត្រង់បន្ទាត់ 23-25, ERN 00966142 ត្រង់បន្ទាត់ 1-3 និង ERN 00966143 ត្រង់បន្ទាត់ 9-12 (ភាសាអង់គ្លេស)។

[5] ឯកសារ **E301/5** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ (បន្ទាប់ពីនេះហៅថា "ឯកសារ E301/5")។

[6] ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ៧០ (បន្ទាប់ពីនេះហៅថា "ឯកសារ E284/4/8")។

[7] *ដូចយោងខាងលើ*។ ផ្នែកសម្រេចសេចក្តី ត្រង់ ERN 00964331។

របស់តុលាការ ICTY និងយុត្តិសាស្ត្រពាក់ព័ន្ធថាមានលក្ខណៈជាការណែនាំ នៅក្នុងការសម្រេចអំពីវិសាលភាពសមស្របនៃការជំនុំជម្រះ[8]។ ដូច្នេះ អង្គជំនុំជម្រះកំណត់កត្តាចំនួនប្រាំពីរ ដែលអាចពាក់ព័ន្ធទៅនឹងការសម្រេចអំពីភាពជាតំណាង៖ ១) ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ២) ចំណាត់ថ្នាក់ និងចរិតលក្ខណៈនៃឧក្រិដ្ឋកម្ម ៣) ទីកន្លែងដែលត្រូវបានលើកឡើងថាមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ៤) ទំហំនៃឧក្រិដ្ឋកម្ម ៥) ជនរងគ្រោះដោយសារឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ៦) អំឡុងរយៈពេលនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ និង ៧) លក្ខណៈជាមូលដ្ឋាននៃរឿងក្តី[9]។

## IV. ទឡ្ហីករណ៍

### ក. សំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២

8. ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រដល់ការដាក់បញ្ចូលមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល ការដ្ឋានធ្វើការ ទំនប់១មករា និង ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង សហករណ៍ត្រាំកក់ ការប្រព្រឹត្តទៅលើជនជាតិចាម និងវៀតណាម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅ ទំនប់១មករា និងនៅសហករណ៍ត្រាំកក់ និងការធ្វើទុក្ខបុកម្នេញលើព្រះពុទ្ធសាសនានៅទីតាំងឧក្រិដ្ឋកម្ម និងទឡ្ហីករណ៍ដែលដាក់ដោយសហព្រះរាជអាជ្ញា ដើម្បីធ្វើយុត្តិកម្មលើការស្នើបញ្ចូលរបស់ពួកគេ។ ការរួមបញ្ចូលគ្នានៃទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុទាំងនេះ បំពេញនូវកត្តាមួយចំនួនដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល ក្នុងការបង្កើតវិសាលភាពដែលជាតំណាងសមស្របនៃការជំនុំជម្រះក្តី។ លើសពីនេះទៀត ផលប្រយោជន៍នៃក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលគ្នា គឺត្រូវបានតំណាងចំពោះកម្រិតជាក់លាក់មួយដោយភាពផ្សេងគ្នានៃភូមិសាស្ត្រនៃទីតាំងឧក្រិដ្ឋកម្ម និងចំនួនដើមបណ្តឹងរដ្ឋប្បវេណីដែលរងផលប៉ះពាល់ដោយបទចោទប្រកាន់ដែលបានស្នើឡើង។

9. ដើមបណ្តឹងរដ្ឋប្បវេណីមានយោបល់ថា ការបន្ថែមទីតាំងឧក្រិដ្ឋកម្ម និងការពង្រីកការចោទប្រកាន់ផ្នែកអង្គហេតុដែលលើសពីសំណើរបស់សហព្រះរាជអាជ្ញា គឺវាចាំបាច់ដើម្បីឈានទៅដល់កម្រិត

---

[8] *ដូចយោងខាងលើ* កថាខណ្ឌ ៦៤។ សូមមើលផងដែរ ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៤២ និងជើងទំព័រ ១០៧។

[9] ឯកសារ **E284/4/8** កថាខណ្ឌ ៦៤។

នៃភាពជាតំណាងសមស្រប ដូចដែលបានប្រគល់អាណត្តិដោយអង្គជំនុំជម្រះតុលាការកំពូល។ សម្រាប់ជា**អាទិភាពទីមួយ** ដើមបណ្តឹងរដ្ឋប្បវេណី ជម្រុញឱ្យអង្គជំនុំជម្រះទទួលយកនូវវិសាលភាពដែលស្នើឡើងដោយសហព្រះរាជអាជ្ញា ជាមួយនឹងការបន្ថែមការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេស ដែលពិពណ៌នាដូចខាងក្រោម៖

## ខ. សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២

### *i. អាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេស*

10. ដើមបណ្តឹងរដ្ឋប្បវេណីស្នើឡើងថា បទឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវដាក់បញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ជាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅទូទាំងប្រទេស[10]។ ការដាក់បញ្ចូលបទឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឡើងនោះ ត្រូវបានគាំទ្រដោយកត្តាស្ទើរតែទាំងអស់ក្នុងចំណោមកត្តាទាំងឡាយដែលត្រូវបានពិពណ៌នានៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការកំណត់វិសាលភាពជាតំណាងសមស្របសម្រាប់សំណុំរឿង ០០២/០២។

11. ការដាក់បញ្ចូលអាពាហ៍ពិពាហ៍ដោយបង្ខំ នឹងធានានូវភាពជាតំណាងនៃពេលវេលា និងទីតាំងភូមិសាស្ត្រដ៏ទូលំទូលាយនៅក្នុងសំណុំរឿង ពីព្រោះអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅទូទាំងទឹកដី និងនៅក្នុងអំឡុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៀត ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់នៃការរំលោភផ្លូវភេទ និងក្រោមទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងអង្គហេតុ គឺមានលក្ខណៈជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សជាមូលដ្ឋានមួយ ក្នុងចំណោមសិទ្ធិមនុស្សជាមូលដ្ឋានទាំងអស់ គឺសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយប្តីប្រពន្ធតាមការជ្រើសរើសដោយខ្លួនឯង ត្រូវបានបដិសេធពីព្រោះប្រជាជនកម្ពុជាយ៉ាងច្រើន ត្រូវបានបង្ខំឱ្យរួមសមគ្គសង្វាស ដែលតាមរយៈនេះ ការរួមភេទត្រូវបានគេតម្រូវ ឬបង្ខំ ហើយការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ត្រូវបានបដិសេធចោល[11]។ អាពាហ៍ពិពាហ៍ដោយបង្ខំក៏ជា បរិបទតែមួយផងដែរ

---

[10] ឯកសារ **D427** ដីកាដំណោះស្រាយ សំណុំរឿង ០០២ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៤៤២ (បន្ទាប់ពីនេះហៅថា "ឯកសារ **D427**")។

[11] ដូចយោងខាងលើ កថាខណ្ឌ ៨៤៩-៨៦០។

នៅក្នុងសំណុំរឿង ០០២ ដែលតាមរយៈនេះ អង្គជំនុំជម្រះសាលាដំបូង នឹងមានឱកាសក្នុងការពិចារណាលើការចោទប្រកាន់យ៉ាងច្បាស់អំពីឧក្រិដ្ឋកម្មលើផ្លូវភេទ និងលើយ៉េនឌ័រ ដែលមានលក្ខណៈ និងធាតុផ្សំពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្សេងៗទៀតប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២ និងភាពមិនអាចខ្វះបាននៃតំណាងសមស្របនៃចរិតលក្ខណៈនៃឧក្រិដ្ឋកម្ម។ បទចោទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បង្កើតបានជាផ្នែកទាំងមូលមួយនៃលក្ខណៈជាមូលដ្ឋាននៃសំណុំរឿង ០០២/០២ ដែលពិចារណាលើការបញ្ហាដាច់ខាតមួយចំពោះបុគ្គលតាមរយៈការអនុវត្តគោលនយោបាយទាំងប្រាំ ដែលដាក់បញ្ចូលទៅនឹងបទបញ្ញត្តិនៃអាពាហ៍-ពិពាហ៍។

12. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧៧៩នាក់ ត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង ០០២ ជាជនរងគ្រោះដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលស្ថិតក្នុងក្រុមនេះក្នុងចំណោម ចំនួនយ៉ាងច្រើនបំផុតនៅក្នុងក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលគ្នា និងបង្ហាញឲ្យឃើញនូវចំនួនដ៏ច្រើននៃជនរងគ្រោះដោយសារឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នេះ មិនថាតែជនរងគ្រោះដែលស្ថិតក្នុង និងក្រៅនៃបក្សកុម្មុយនីស្តកម្ពុជា (“បកក”) នោះទេ គឺពួកគេមកពីគ្រប់ជាន់ថ្នាក់នៃសង្គម។ យ៉ាងហោចណាស់ ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៤៧៤ នាក់ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ គឺជាជនរងគ្រោះផ្ទាល់ដែលអាចផ្តល់នូវភស្តុតាងបញ្ជាក់យ៉ាងច្បាស់ និងលម្អិតស្តីអំពីការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងភូមិភាគនីមួយៗ ក្នុងចំណោមភូមិភាគទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយប្រសិនបើមិនបាននៅគ្រប់ខេត្តទាំងអស់ទេ ក៏នៅក្នុងខេត្តភាគច្រើនក្នុងចំណោមខេត្តបច្ចុប្បន្ននៃប្រទេសកម្ពុជាដែរ។ ដូច្នេះហើយ ការដាក់បញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេស នឹងពង្រឹងមូលដ្ឋានភស្តុតាងសម្រាប់ធាតុរឹងមាំនៃការវាយប្រហារ “មានលក្ខណៈរាលដាល ឬជាប្រព័ន្ធ” នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

13. ការដាក់បញ្ចូលបទចោទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេស នឹងមិនប៉ះពាល់ដល់ការពន្លឿននៃការជំនុំជម្រះក្តីនោះទេ។ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រមើលឃើញនូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពនៃប្រធានបទនេះនៅពេលសវនាការ ដោយសារតែការពង្រីករហូតទៅដល់វិសាលភាពទូទាំងប្រទេស នឹងមិនត្រូវការចំនួនថ្ងៃសវនាការបន្ថែមច្រើនហួសហេតុនោះឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីស្នើ ឲ្យស្តាប់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីម្នាក់មកពីភូមិភាគនីមួយៗ និងអ្នកជំនាញម្នាក់ស្តីអំពី ការអនុវត្តជាទូទៅនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបំពេញបន្ថែមដោយគំរូជាតំណាងនៃ កំណត់ហេតុនៃការស្តាប់ចម្លើយ និងចម្លើយជា

លាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមកពីភូមិភាគនីមួយៗ។ ភស្តុតាងជាច្រើនក្នុងចំណោមភស្តុតាងនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និងត្រូវបានយកមកធ្វើជាមូលដ្ឋាន នៅក្នុងផ្នែកស្តីពីគោលនយោបាយនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៃសារណាបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១ របស់ដើមបណ្តឹងរដ្ឋប្បវេណី[12]។ ដើមបណ្តឹងរដ្ឋប្បវេណីប៉ាន់ប្រមាណថា ការបង្ហាញភស្តុតាងដោយដើមបណ្តឹងរដ្ឋប្បវេណីអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈឬហិង្សាផ្លូវភេទនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ នឹងត្រូវការថ្ងៃសវនាការប្រហែលជា ៥ថ្ងៃ។

14. នៅក្នុងការបន្ថែមទៅនឹងសំណើជាអាទិភាពទីមួយដែលបានពិពណ៌នានៅក្នុងកថាខណ្ឌទី ៨ ដល់ ១៣ ខាងលើ ដើមបណ្តឹងរដ្ឋប្បវេណីស្នើឡើងដូចតទៅនូវទីតាំងឧក្រិដ្ឋកម្ម និងអង្គហេតុដែលបានចោទប្រកាន់បន្ថែមសម្រាប់ការពិចារណារបស់អង្គជំនុំជម្រះ **ជាអាទិភាពទីពីរ។**

### *ii. ការប្រព្រឹត្តចំពោះពុទ្ធសាសនិកនៅទូទាំងប្រទេស*

15. បន្ថែមទៅនឹងសំណើរបស់ព្រះរាជអាជ្ញាស្នើសុំឱ្យកាត់សេចក្តីឧក្រិដ្ឋកម្មទាំងឡាយ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើពុទ្ធសាសនិក តាមរយៈសហករណ៍ត្រាំកក់នោះ[13] ដើមបណ្តឹងរដ្ឋប្បវេណីស្នើឡើងថា ការប្រព្រឹត្តទៅលើពុទ្ធសាសនិក គួរត្រូវបានយកមកពិចារណានៅក្នុងវិសាលភាពទូទាំងប្រទេស ដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២[14]។

16. ប្រជាជនកម្ពុជាជាច្រើនដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាជនរងគ្រោះដោយសារការលុបបំបាត់ចោល និងការវាយប្រហារទៅលើការប្រតិបត្តិជំនឿ/សាសនា និងអ្នកប្រតិបត្តិសាសនា ដែលគ្របដណ្តប់លើវិសាលភាពពេលវេលាទាំងមូលនៃ សំណុំរឿង ០០២[15]។ ដូច្នេះ វិសាលភាព និងទំហំនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ដែល ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើ

---

[12] សូមមើល ឯកសារ **E295/6** សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើសំណុំរឿង ០០២/០១ ជាមួយឧបសម្ពន្ធសម្ងាត់ ១-៤ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២០៥-២២៥។

[13] ឯកសារ **E301/2** កថាខណ្ឌ ១៤។

[14] ឯកសារ **D427** កថាខណ្ឌ ៧៤៣ (ដែលបញ្ជាក់ថា ការលុបបំបាត់សាសនា ការបំផ្លិចបំផ្លាញវត្តអារាម និងការប្រើប្រាស់វត្តអារាមក្នុងគោលបំណងផ្សេងទៀត។ល។ បានកើតជាទូទៅនៅគ្រប់ខេត្តទាំងអស់នៃប្រទេសកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ [...]")។

[15] ឯកសារ **D427** កថាខណ្ឌ ២០៥។

ពុទ្ធសាសនិកជន មានលក្ខណៈធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋានគ្រឹះផ្នែកសាសនា និងបទដ្ឋានវប្បធម៌ ដែលបានជួយទ្រទ្រង់ជីវិតរស់នៅរបស់ប្រជាជនកម្ពុជាភាគច្រើន។ វិសាលភាពដ៏ធំធេងនៃឧក្រិដ្ឋកម្មនេះ គ្របដណ្តប់ទៅលើប្រជាជនភាគច្រើនក្នុងរបបកម្ពុជា ប្រជាធិបតេយ្យនៅក្នុងវិសាលភាពទាំងមូលនៃរបបនេះ ហើយការណ៍ពិតជាក់ស្តែងនេះគួរត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ លើសពីនេះទៀត ការធ្វើបាបពុទ្ធសាសនិកនៅទូទាំងប្រទេស ទាក់ទិននឹងទិដ្ឋភាពជាមូលដ្ឋានមួយនៃទិសដៅរបស់បក្សកុម្មុយនីស្តកម្ពុជា "ក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័ស"[16] តាមរយៈការបង្កើតសង្គមដែលមិន ជឿសាសនា និងមានលក្ខណៈតែមួយ"[17]។

17. យ៉ាងហោចណាស់ ជនរងគ្រោះផ្ទាល់ដែលជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣០នាក់ ហើយប្រហែលជាច្រើនជាងនេះទៀត អាចផ្តល់ភ័ស្តុតាងបានអំពីការប្រព្រឹត្តទៅលើពុទ្ធសាសនិក[18]។ ដើមបណ្តឹងរដ្ឋប្បវេណីប៉ាន់ប្រមាណថា ការបង្ហាញភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការប្រព្រឹត្តទៅលើពុទ្ធសាសនិក នឹងត្រូវការថ្ងៃសវនាការប្រមាណ ៥ថ្ងៃ។

### *iii. ការដ្ឋានទំនប់ត្រពាំងថ្ម*

18. ការដ្ឋានទំនប់ត្រពាំងថ្មត្រូវបានដាក់បញ្ចូល នៅក្នុងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្នែកខ្លះពីព្រោះវាបញ្ជាក់អំពីប្រធានបទជាមូលដ្ឋានមួយនៃរឿងក្តី ការប្រើប្រាស់ពលកម្មដោយបង្ខំដែលត្រូវបានចោទប្រកាន់ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ផ្សេងៗទៀតនៅឯការដ្ឋាន ដើម្បីសម្រេចទិសដៅនយោបាយ និងសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ ដូចដែលបានស្តែងឡើងនៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស តាមរយៈការបង្កើនផលិតផលស្រូវឱ្យបានជាអតិបរមា[19]។

---

[16] ដូចយោងខាងលើ កថាខណ្ឌ ១៥៦។

[17] ដូចយោងខាងលើ កថាខណ្ឌ ២០៧។

[18] ការវិភាគទៅលើដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមចំនួន ១០១នាក់ ដែលត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះចំពោះសំណុំរឿង ០០២/០២ បច្ចុប្បន្នកំពុងត្រូវបានធ្វើឡើងដើម្បីកំណត់ថាតើព្យសនកម្មដែលបានទទួលរងណាមួយជាជនរងគ្រោះផ្ទាល់។

[19] ឯកសារ **D427** កថាខណ្ឌ ៣២៤ (ដែលដកស្រង់ ការដាស់តឿនរបស់បក្សកុម្មុយនីស្តកម្ពុជាឱ្យអ្នកធ្វើការ "បូជាអ្វីៗទាំងអស់ដើម្បីផលិតស្រូវឱ្យបានជាអតិបរមា")។

19. ជាពិសេស ការដ្ឋាននេះគឺជាការបន្ថែមដ៏សំខាន់មួយទៅនឹងសំណើរបស់ព្រះរាជអាជ្ញាអំពីការដ្ឋានទំនប់១មករា ដោយសារវាផ្តល់នូវភាពជាតំណាងផ្នែកភូមិសាស្ត្រ សម្រាប់ភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាដែលទីកន្លែងនេះគឺជាតំបន់មួយមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែលបានស្នើឡើងដោយព្រះរាជអាជ្ញា។ លើសពីនេះទៀត ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដែលរួមមានបទមនុស្សឃាត (រួមទាំងការកំណត់មុខសញ្ញាសម្លាប់ស្ត្រីមានផ្ទៃពោះ[20]) ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ[21] ក្នុងចំណោមប្រការផ្សេងទៀត ព្រមទាំងចំនួននៃជនរងគ្រោះដែលបានទទួលរងផលប៉ះពាល់ដោយសារឧក្រិដ្ឋកម្មទាំងនេះ (តាមការរាយការណ៍ថា មានចំនួនរាប់ពាន់នាក់ទៅដល់រាប់ម៉ឺននាក់)[22] ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅទំនប់ត្រពាំងថ្ម នោះ មានកម្រិតខ្ពស់មែនទែន។

20. យ៉ាងហោចណាស់ជនរងគ្រោះផ្ទាល់ដែលជាដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៥៩នាក់ អាចផ្តល់ភ័ស្តុតាងបានអំពីប្រតិបត្តិការ និងស្ថានភាពនៅឯការដ្ឋានទំនប់ត្រពាំងថ្ម។ ដើមបណ្តឹងរដ្ឋប្បវេណីប៉ាន់ប្រមាណថា ការបង្ហាញភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការដ្ឋាននេះ នឹងត្រូវការថ្ងៃសវនាការប្រហែល ៤ថ្ងៃ។

### *iv. មន្ទីរសន្តិសុខភូមិភាគឧត្តរ*

21. សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបញ្ចូលមន្ទីរសន្តិសុខនៅភូមិភាគឧត្តរ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ គឺដើម្បីឱ្យមានភាពជាតំណាងផ្នែកទីតាំងភូមិសាស្ត្រនៃភូមិភាគឧត្តរនៅក្នុងការចោទប្រកាន់ដែលនឹងត្រូវយកមកជំនុំជម្រះនៅក្នុងវគ្គបន្ទាប់ និងដើម្បីបំពេញបន្ថែមលើសំណើសុំដែលធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា។

22. ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ វិសាលភាពនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅមន្ទីរសន្តិសុខភូមិភាគឧត្តរមានលក្ខណៈធ្ងន់ធ្ងរ និងប៉ះពាល់លើជនរងគ្រោះជាច្រើននាក់។ បុគ្គល

---

[20] *ដូចយោងខាងលើ* កថាខណ្ឌ ១៣៧៣ និង ៣៤៩។

[21] *ដូចយោងខាងលើ* កថាខណ្ឌ ១៣៨១ (ការសម្លាប់រង្គាល) កថាខណ្ឌ ១៣៩១ (ការធ្វើឱ្យទៅជាទាសករ) កថាខណ្ឌ ១៤១៦ និង ៣៤៦ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ) កថាខណ្ឌ ១៤៤៧ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) និង កថាខណ្ឌ ១៤៧០ (ការបាត់ខ្លួនដោយបង្ខំ)។

[22] *ដូចយោងខាងលើ* កថាខណ្ឌ ៣៣៤។

ភាគច្រើន រួមទាំងស្ត្រី (ពេលខ្លះ ស្ត្រីមានផ្ទៃពោះ) កុមារ និងទារក កម្មាភិបាលបក្សកុម្មុយនីស្ត កម្ពុជា អ្នកជាប់និន្នាការជាមួយនឹងរបបសាធារណរដ្ឋខ្មែរ ព្រមទាំង ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ត្រូវបានគេឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខភូមិភាគឧត្តរ ដែលតាមរបាយការណ៍ អាចមានលទ្ធភាពដាក់អ្នកទោសបានចំនួន ៥០០ នាក់[23]។ ឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់នៅក្នុងទីតាំងនេះស្ថិតនៅក្នុងចំណោមឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត រួមមានដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងការបាត់ខ្លួនដោយបង្ខំ[24]។

23. មន្ទីរសន្តិសុខនេះក៏ត្រូវបានគេចោទប្រកាន់ថា បានបើកដំណើរការស្ទើរតែពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហេតុដូច្នេះ វារួមបញ្ចូលឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងនៅទូទាំងរបបនោះ[25]។ ករណីដែលថា ការសួរចម្លើយដែលប្រព្រឹត្តឡើងដោយកម្មាភិបាលនៅក្នុងមន្ទីរសន្តិសុខនេះ ត្រូវបានគេចោទប្រកាន់ថាបានកើតឡើងនៅក្នុងបរិវេណកៀកនឹងអតីតវត្តមួយកន្លែងនោះ[26] ក៏ផ្តល់នូវភស្តុតាងពាក់ព័ន្ធស្តីពីការលុបបំបាត់សាសនា និងគោលការណ៍ស្តីពីការកំណត់មុខសញ្ញាលើពុទ្ធសាសនិកជននៅក្នុងភូមិភាគឧត្តរ។ ម្យ៉ាងវិញទៀត អំពើដែលបានចោទប្រកាន់ថាបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខភូមិភាគឧត្តរ ជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងលក្ខណៈសារវ័ន្តនៃរឿងក្តីដែលពាក់ព័ន្ធនឹងគោលបំណងរួមនៃ "ការការពារបក្ស ប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ តាមគ្រប់មធ្យោបាយដែលចាំបាច់"[27]។

24. ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះផ្ទាល់ យ៉ាងហោចណាស់ សរុបចំនួន ១៨ នាក់ អាចមកផ្តល់ភស្តុតាងស្តីពីចំណុចទាំងនេះ និងចំណុចផ្សេងទៀតពាក់ព័ន្ធនឹងប្រតិបត្តិការនៃមន្ទីរសន្តិសុខ

---

[23] *ដូចខាងលើ* កថាខណ្ឌ ៥៧៦។

[24] *ដូចខាងលើ* កថាខណ្ឌ ១៣៧៣ (ការធ្វើមនុស្សឃាត) កថាខណ្ឌ ១៣៨១ (ការសម្លាប់រង្គាល) កថាខណ្ឌ ១៣៩១ (ការធ្វើឱ្យទៅជាទាសករ) កថាខណ្ឌ ១៤០២ (ការដាក់ក្នុងមន្ទីរឃុំឃាំង) កថាខណ្ឌ ១៤០៨ (ការធ្វើទារុណកម្ម) កថាខណ្ឌ ១៤១៦ (ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ) កថាខណ្ឌ ១៤៧០ (ការបាត់ខ្លួនដោយបង្ខំ)។

[25] *ដូចខាងលើ* កថាខណ្ឌ ៥៧២។

[26] *ដូចខាងលើ* កថាខណ្ឌ ៥៧៣។

[27] *ដូចខាងលើ* កថាខណ្ឌ ១៥៦។

ភូមិភាគឧត្តរ[28]។ ដើមបណ្តឹងរដ្ឋប្បវេណីប៉ាន់ស្មានថា ការបង្ហាញភស្តុតាងដោយដើមបណ្តឹងរដ្ឋប្បវេណីស្តីពីមន្ទីរសន្តិសុខនេះនឹងត្រូវការរយៈពេលប្រហែលជា ៣ថ្ងៃនៃថ្ងៃសវនាការ។

### v. មន្ទីរសន្តិសុខកោះខ្សែង

25. ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់បញ្ចូលមន្ទីរសន្តិសុខកោះខ្សែង នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ អំពើដែលបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅក្នុងទីតាំងនេះមានលក្ខណៈដ៏ធ្ងន់ធ្ងរ ហើយមានលក្ខណៈប្លែកពីមន្ទីរសន្តិសុខផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនាំឱ្យសហចៅក្រមស៊ើបអង្កេតឈានដល់ការពិពណ៌នាស្ថានភាពរស់នៅកោះខ្សែងនេះថាមាន *"សភាពវេទនាណាស់"*[29]។ ដីកាដំណោះស្រាយរៀបរាប់អំពីការចោទប្រកាន់ថា កុមារ ទារក និងស្ត្រីមានផ្ទៃពោះតាមការចោទប្រកាន់ ត្រូវបានគេឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ[30] អ្នកទោសត្រូវបានគេបង្អត់អាហារ ហើយបង្ខំឱ្យដេកលើលាមករបស់ពួកគេ[31] ហើយគ្រួសារទាំងមូលត្រូវបានគេជ្រមុជចូលក្នុងទឹក[32]។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរាយការណ៍ថា អ្នកទោសត្រូវបានគេវះពោះយកថ្លើមប្រម៉ាត់ ហើយគ្រឿងក្នុងរបស់ពួកគេត្រូវបានកម្មាភិបាលនៃគុកយកមកបរិភោគ[33]។ អ្នកទោសស្ត្រីតាមការចោទប្រកាន់ ក៏ត្រូវបានទទួលរងនូវការសម្រាតសម្លៀកបំពាក់ដោយបង្ខំ និងការឃាយីនិងការបំពានផ្លូវភេទផងដែរ[34]។

26. ហេតុដូច្នេះ ឧក្រិដ្ឋកម្មទាំងឡាយ ដែលបានចោទប្រកាន់លើមន្ទីរសន្តិសុខកោះខ្សែងនៅក្នុងដីកាដំណោះស្រាយស្ថិតនៅក្នុងចំណោមឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត រួមទាំងអំពើប្រល័យពូជសាសន៍ ការ

---

[28] តួលេខនេះតំណាងនូវចំនួនដើមបណ្តឹងដែលបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២ ដោយ ក.ស.ច.ស ដោយផ្អែកលើមូលដ្ឋាននៃព្យសនកម្ម ក្នុងនាមជាជនរងគ្រោះផ្ទាល់នៅមន្ទីរសន្តិសុខភូមិភាគឧត្តរ ប៉ុន្តែ ពុំបានបញ្ចូលជនរងគ្រោះផ្ទាល់ ដែលអាចត្រូវបានទទួលស្គាល់ដោយ អ.ប.ជ ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងពាក់ព័ន្ធនឹងទីតាំងនេះ។

[29] ឯកសារ D427 កថាខណ្ឌ ៥២៧ (ការគូសបញ្ជាក់បន្ថែម)។

[30] *ដូចខាងលើ* កថាខណ្ឌ ៥២៥។

[31] *ដូចខាងលើ* កថាខណ្ឌ ៥២៧។

[32] *ដូចខាងលើ* កថាខណ្ឌ ៥៣១។

[33] *ដូចខាងលើ* កថាខណ្ឌ ៥៣១ និងលេខយោងជើងទំព័រ ២២៩៥ និង ២២៩៦។

[34] *ដូចខាងលើ* កថាខណ្ឌ ៥២៩។

ធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងការបាត់ខ្លួនដោយបង្ខំ[35]។

27. លើសពីនេះ មន្ទីរសន្តិសុខនេះក៏ត្រូវបានគេចោទប្រកាន់ថាបានបើកដំណើរការស្ទើរតែពេញមួយអំឡុងពេលយុត្តាធិការពេលវេលានៃ អ.វ.ត.ក[36] ហើយអំពើទាំងឡាយដែលបានចោទប្រកាន់ថាបានកើតឡើងនៅកោះខ្យងមានការជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងលក្ខណៈសារវ័ន្តនៃរឿងក្តី ដែលពាក់ព័ន្ធនឹងគោលបំណងរួមនៃ "ការការពារបក្ស ប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅតាមគ្រប់មធ្យោបាយដែលចាំបាច់"[37]។

28. ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះផ្ទាល់ យ៉ាងហោចណាស់ សរុបចំនួន ៩ នាក់ អាចមកផ្តល់ភស្តុតាងស្តីពីចំណុចទាំងនេះ និងចំណុចផ្សេងទៀតពាក់ព័ន្ធនឹងប្រតិបត្តិការនៃមន្ទីរសន្តិសុខកោះខ្យង[38]។ ដើមបណ្តឹងរដ្ឋប្បវេណីប៉ាន់ស្មានថា ការបង្ហាញភស្តុតាងដោយដើមបណ្តឹងរដ្ឋប្បវេណីស្តីពីមន្ទីរសន្តិសុខនេះនឹងត្រូវការរយៈពេលប្រហែលជា ៣ថ្ងៃនៃថ្ងៃសវនាការ។

### *vi. ការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងដំណាក់កាលទីបី និងការបោសសម្អាតពាក់ព័ន្ធនឹងភូមិភាគបូព៌ា*

29. ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យដាក់ឧក្រិដ្ឋកម្មនៃការផ្លាស់ទីលំនៅដោយបង្ខំ នៅក្នុងដំណាក់កាលទីបី និងការបោសសំអាតដែលពាក់ព័ន្ធនៅភូមិភាគបូព៌ា បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដើម្បីជាមធ្យោបាយធ្វើយ៉ាងណាឱ្យមានភាពជាតំណាងផ្នែកទីតាំងភូមិសាស្ត្រឱ្យបានត្រឹមត្រូវនៃរឿងក្តី ព្រមទាំងដើម្បីធ្វើយ៉ាងណាឱ្យលក្ខណៈដោយឡែកនៃការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងដំណាក់កាលនេះ មានភាពជាតំណាងនៅក្នុងកិច្ចដំណើរការនីតិវិធី។ ការដាក់បញ្ចូលការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងដំណាក់កាលទីបី និងការបោសម្អាតពាក់ព័ន្ធផ្សេងទៀត នឹងបំពេញ

---

[35] *ដូចខាងលើ* កថាខណ្ឌ ៥៣០ (ប្រល័យពូជសាសន៍) កថាខណ្ឌ ១៣៧៣ (ការធ្វើមនុស្សឃាត) ១៣៨១ (ការសម្លាប់រង្គាល) ១៣៩១ (ការធ្វើឱ្យទៅជាទាសករ) ១៤០៨ (ការធ្វើទារុណកម្ម) ១៤១៦ (ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ) ១៤៧០ (ការបាត់ខ្លួនដោយបង្ខំ)។

[36] *ដូចខាងលើ* កថាខណ្ឌ ៥១៦។

[37] *ដូចខាងលើ* កថាខណ្ឌ ១៥៦។

[38] តួលេខនេះតំណាងនូវចំនួនដើមបណ្តឹងដែលបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២ ដោយ ក.ស.ច.ស ដោយផ្អែកលើមូលដ្ឋាននៃព្យសនកម្ម ក្នុងនាមជាជនរងគ្រោះផ្ទាល់នៅមន្ទីរសន្តិសុខកោះខ្យង ប៉ុន្តែ ពុំបានបញ្ចូលជនរងគ្រោះផ្ទាល់ ដែលអាចត្រូវបានទទួលស្គាល់ដោយ អ.ប.ជ ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងពាក់ព័ន្ធនឹងទីតាំងនេះ។

បន្ថែមលើសំណើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញាស្តីពីវិសាលភាព ដោយវាបានធានាថា ឧក្រិដ្ឋកម្មនេះ និងតំបន់នៅក្នុងប្រទេសដែលឧក្រិដ្ឋកម្មនេះបានកើតឡើង ពោលគឺ ភូមិភាគបូព៌ា ពុំត្រូវបានដកចេញពីកិច្ចដំណើរការនីតិវិធី។ ការចោទប្រកាន់ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំក្នុងដំណាក់កាលទីបី និងការបោសសម្អាតពាក់ព័ន្ធផ្សេងទៀតមានការជាប់ទាក់ទងយ៉ាងខ្លាំង និងបំពេញបន្ថែមលើភស្តុតាងស្តីពីមន្ទីរសន្តិសុខ ស-២១ ជាពិសេស ការបោសសម្អាតដែលបានចោទប្រកាន់លើកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅក្នុងភូមិភាគបូព៌ា និងសមាជិកកងទ័ពបដិវត្តន៍កម្ពុជា[39]។

30. ការចោទប្រកាន់ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងដំណាក់កាលទីបី និងការបោសសម្អាតពាក់ព័ន្ធផ្សេងទៀតក៏រួមបញ្ចូលជនរងគ្រោះជាច្រើននាក់ រួមទាំងកម្មាភិបាល និងកងទ័ពបក្សកុម្មុនីស្តកម្ពុជា និងអ្នកពាក់ព័ន្ធជាមួយលេខាភូមិភាគបូព៌ាឈ្មោះ **សោ ភឹម** អតីតអ្នកជាប់និន្នាការជាមួយនឹងរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី ព្រះសង្ឃពុទ្ធសាសនា ជនជាតិចាម ជនជាតិចិន ខ្មែរកម្ពុជាក្រោម និងជនជាតិវៀតណាម[40]។ ឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ប្រឆាំងនឹងក្រុមមួយនេះ ឬ ច្រើនជាងនេះគឺស្ថិតនៅក្នុងចំណោមឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត រួមទាំង ការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ និងនយោបាយ[41]។

31. ការបោសសម្អាតដែលត្រូវបានចោទប្រកាន់ថាបានជម្រុញឲ្យកើតឡើង នៅពីក្រោយការផ្លាស់ទីលំនៅដោយបង្ខំក្នុងដំណាក់កាលទីបី[42] ក៏ជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងលក្ខណៈសារវ័ន្តនៃរឿងក្តីដែលពាក់ព័ន្ធនឹងគោលបំណងរួមនៃ “ការការពារបក្ស ប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ តាមគ្រប់មធ្យោបាយដែលចាំបាច់”[43]។

32. ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះផ្ទាល់ យ៉ាងហោចណាស់ សរុបចំនួន ១៣៩ នាក់ អាចមកផ្តល់ភស្តុតាងស្តីពីចំណុចទាំងនេះ និងចំណុចផ្សេងទៀតពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំ

---

[39] *សូមមើល* ឯកសារ D427 កថាខណ្ឌ ២៨៥ កថាខណ្ឌ ២៩០ កថាខណ្ឌ ២៩៦ និងកថាខណ្ឌ ៤៣១។

[40] *ដូចខាងលើ* កថាខណ្ឌ ២៨៥។

[41] *ដូចខាងលើ* កថាខណ្ឌ ១៣៧៣ (ការធ្វើមនុស្សឃាត) ១៤២២ (ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍) និងកថាខណ្ឌ ១៤១៥ (ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ)។

[42] *ដូចខាងលើ* កថាខណ្ឌ ២៨៣។

[43] *ដូចខាងលើ* កថាខណ្ឌ ១៥៦។

ក្នុងដំណាក់កាលទីបី។ ដើមបណ្ដឹងរដ្ឋប្បវេណីប៉ាន់ស្មានថា ការបង្ហាភស្តុតាងដោយដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងដំណាក់កាលទីបី និងការបោសសម្អាតពាក់ព័ន្ធផ្សេងទៀតនឹងត្រូវការរយៈពេលប្រហែលជា ៥ ថ្ងៃនៃថ្ងៃសវនាការ។

33. ដោយគោរពតាមការកំណត់ពេលវេលាដែលបានស្នើសម្រាប់ការបន្ថែមទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុនីមួយៗដែលបានពិភាក្សាខាងលើ ដើមបណ្ដឹងរដ្ឋប្បវេណីកត់សំគាល់ថាសំណើទាំងនេះ គឺត្រូវបានបង្កើតឡើងផ្អែកតែលើមូលដ្ឋាននៃភស្តុតាងដើមបណ្ដឹងរដ្ឋប្បវេណី។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគាត់ក៏បានគូសបញ្ជាក់ផងដែរថា ភស្តុតាងនេះ វាស៊ីគ្នាជាមួយនឹងភស្តុតាងដែលស្នើឡើងដោយសហព្រះរាជអាជ្ញា ដូច្នេះហើយ ទើបពេលវេលាជាក់ស្ដែងដែលបានតម្រូវដើម្បីបំភ្លឺទាំងភស្តុតាងរបស់សហព្រះរាជអាជ្ញា និងភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុទាំងនេះ នឹងមានចំនួនតិចជាងផលបូកសរុប នៃចំនួនថ្ងៃជម្រះក្ដីដែលបានប៉ាន់ប្រមាណដោយភាគីនីមួយៗ។

34. ជាសរុបមក សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំបន្ថែមទីតាំងឧក្រិដ្ឋកម្ម ឬ ការចោទប្រកាន់អង្គហេតុនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចបានបញ្ជាក់ខាងលើនឹងតម្រូវឱ្យបញ្ចូលលេខកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយដូចខាងក្រោម ដើម្បីឆ្លើយតបទៅនឹងផ្នែកពាក់ព័ន្ធស្ដីពីសំអាងហេតុនៃឧក្រិដ្ឋកម្ម៖

ក. *ការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃការរៀបការដោយបង្ខំ៖* កថាខណ្ឌ ៨៤២-៨៦១។

ខ. *ការប្រព្រឹត្តលើពុទ្ធសាសនិកជន៖* កថាខណ្ឌ ៧៤០-៧៤៣។

គ. *ការដ្ឋានទំនប់ត្រពាំងថ្ម៖* កថាខណ្ឌ ៣២៣-៣៥០។

ឃ. *មន្ទីរសន្តិសុខភូមិភាគឧត្តរ៖* កថាខណ្ឌ ៥៧២-៥៨៨។

ង. *មន្ទីរសន្តិសុខកោះខ្សែង៖* កថាខណ្ឌ ៥១៦-៥៣៤ និង

ច. *ការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងដំណាក់កាលទី ៣ និងការបោសសម្អាតពាក់ព័ន្ធផ្សេងទៀត៖* កថាខណ្ឌ ២៨៣-៣០១។

35. លើសពីនេះ សំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីតម្រូវឱ្យបញ្ចូលកថាខណ្ឌពាក់ព័ន្ធនឹងផ្នែកស្ដីពីសំអាងហេតុនៃសហឧក្រិដ្ឋកម្មរួម តួនាទីរបស់ជនជាប់ចោទ និងជម្លោះប្រដាប់អាវុធ នៅក្នុងដីកាដំណោះស្រាយ ដូចខាងក្រោម៖

ក. *សំអាងហេតុនៃសហឧក្រិដ្ឋកម្មរួម*៖ កថាខណ្ឌ ១៥៦-១៥៩ កថាខណ្ឌ ១៦៣ និង កថាខណ្ឌ ១៦៦-២២០។

ខ. *តួនាទីរបស់ជនជាប់ចោទ*៖ កថាខណ្ឌ ៩០២-៩៧៦ កថាខណ្ឌ ៩៧៨-៩៩២ កថាខណ្ឌ ១១៦៣-១១៩២ និងកថាខណ្ឌ ១១៩៤-១១៩៩ និង

គ. *ជម្លោះប្រដាប់អាវុធ*៖ កថាខណ្ឌ ១៥០-១៥៥ កថាខណ្ឌ ៩៩៣ និងកថាខណ្ឌ ១២០០។

## ខ. ការទម្លាក់បទចោទ

36. ដើមបណ្ដឹងរដ្ឋប្បវេណី ជំទាស់យ៉ាងខ្លាំងទៅនឹងដំណោះស្រាយណាមួយដែលនាំឱ្យមានការទម្លាក់ដោយច្បាស់លាស់ ឬ *ដោយព្រឹត្តហេតុ* នូវបទចោទ និង/ឬ កាលៈទេសៈអង្គហេតុពាក់ព័ន្ធ (ដូចជាទីតាំងឧក្រិដ្ឋកម្ម) ចេញពីសំណុំរឿង ០០២ ពីព្រោះថា ប្រសិនបើធ្វើដូច្នេះ គឺវាប្រឆាំងនឹងផលប្រយោជន៍នៃយុត្តិធម៌ និងគោលការណ៍នានានៃច្បាប់ព្រហ្មទណ្ឌកម្ពុជា[44]។ ម្យ៉ាងវិញទៀត ជនរងគ្រោះ ដែលជាដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើននាក់ មានបំណងយ៉ាងច្បាស់លាស់ចង់រក្សាទុកលទ្ធភាពឱ្យយកការចោទប្រកាន់*ទាំងអស់* ដែលបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ មកធ្វើការវិនិច្ឆ័យ។ ទោះបីជាយ៉ាងនេះក្ដី ដើមបណ្ដឹងរដ្ឋប្បវេណីជឿជាក់ថា ការពិភាក្សាសម្រេចលើបញ្ហានេះនឹងពុំបង្កជាឧបសគ្គអ្វីដល់អង្គជំនុំជម្រះ ក្នុងការចេញសេចក្ដីសម្រេចឱ្យបានទាន់ពេលវេលាលើវិសាលភាពនៃសំណុំរឿង ០០២/០២ នោះទេ។

## V. សេចក្ដីសន្និដ្ឋាន

**37.** ដើមបណ្ដឹងរដ្ឋប្បវេណី ជម្រុញឱ្យអង្គជំនុំជម្រះដើម្បីស្វែងរកឱ្យឃើញថាតម្រូវការសម្រាប់ភាពជាតំណាងភូមិសាស្ត្រនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ជាពិសេសនៅភូមិភាគឧត្តរ

---

[44] សូមមើលឧទាហរណ៍ មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ (ដែលផ្ដល់ជូននូវចំណុចមួយចំនួនអំពីមូលហេតុនៃការរលត់បណ្ដឹងអាជ្ញា ដែលរួមមាន មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ)។

ភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា ទំនាក់ទំនងរវាងទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុដែលបានស្នើឡើងចំពោះលក្ខណៈមូលដ្ឋាននៃរឿងក្តី ភាពធ្ងន់ធ្ងរ និងទំហំនៃឧក្រិដ្ឋកម្មដែលរាប់បញ្ចូលទាំងចំនួននៃជនរងគ្រោះដែលរងផលប៉ះពាល់ដោយសារឧក្រិដ្ឋកម្ម តម្រូវឱ្យមានការយល់ព្រមតាមសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឈានទៅដល់លក្ខខណ្ឌនៃភាពជាតំណាងសមស្របនៅក្នុងសំណុំរឿង ០០២/០២។

**ដោយផ្អែកលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ** ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. **ទទួលយក**សំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម និងឧក្រិដ្ឋកម្មទាំងឡាយ សុំដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

ខ. **សម្រេច**ដាក់បញ្ចូលការដ្ឋានត្រពាំងថ្ម មន្ទីរសន្តិសុខភូមិភាគឧត្តរ និងមន្ទីរសន្តិសុខកោះខ្សែង និងការជម្លៀសដោយបង្ខំដំណាក់កាលទីបី និងការបោសសំអាតដែលពាក់ព័ន្ធនៅភូមិភាគបូព៌ា ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ និង

គ. **បញ្ជាក់ថា** វិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវដាក់បញ្ចូលបទចោទនៃការរៀបការដោយបង្ខំ និងបទល្មើសនៃការរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃការរៀបការដោយបង្ខំ ព្រមទាំងការចោទប្រកាន់អង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តលើពុទ្ធសាសនិកជននៅទូទាំងប្រទេស។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើសុំរបស់យើងខ្ញុំដោយសេចក្តីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ | ពេជ អង្គ<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីអន្តរជាតិនាំមុខ | Montpellier | |